បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 17 ខែ 06 ឆ្នាំ 2003



# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

២៩-៦-២០០១ - ព្រះរាជក្រម នស/រកម/០៦០១/០៦ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ១៥៧៨

២៩-៦-២០០១ - ព្រះរាជក្រម នស/រកម/០៦០១/០៧ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប៉ូឡូញ ១៥៨០

២៩-៦-២០០១ - ព្រះរាជក្រម នស/រកម/០៦០១/០៨ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីដំណោះស្រាយវិវាទពាក់ព័ន្ធទៅនឹងការវិនិយោគ រវាងបណ្តារដ្ឋ និងបុគ្គល នៃរដ្ឋដទៃ ១៥៨២

### ២-ព្រះរាជក្រឹត្យ

២៤-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៩ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនលោក **ហ្វូខ ម៉េងស៊ុន** ១៥៨៤

២៦-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១២ តែងតាំងឯកឧត្តមបណ្ឌិត **ស៊ា គុសល** ជាអគ្គាធិការនៃអគ្គាធិការដ្ឋាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១៥៨៥

២៩-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៣ តែងតាំង ឯកឧត្តម **ឃឹម សារិទ្ធ** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ១៥៨៦

២៩-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៤ តែងតាំងលោក **លឹម រស់** ជាឧកញ៉ា ១៥៨៧

៣០-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៥ តែងតាំងឯកឧត្តម **ហ៊ុន ស៊ីថា** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ១៥៨៧

៣០-៦-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៦ តម្លើងឋានន្តរសក្តិ ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ចៅ តុល** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី ជាឧត្តមសេនីយ៍ទោ ១៥៨៨

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៥-៦-២០០១ - អនុក្រឹត្យ លេខ ៥៤ អនក្រ.បក ស្តីពីការ ផ្ទេរឥណទានថវិកា ១៥៨៩

២៥-៦-២០០១ - អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៥៩១

២៥-៦-២០០១ - អនុក្រឹត្យ លេខ ៥៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៥៩៣

២៨-៦-២០០១ - អនុក្រឹត្យ លេខ ៥៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសីលា ១៥៩៤

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦០៣

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧១ អនក្រ.តត ស្តីពីការ តែងតាំងមន្ត្រីរាជការ ១៦០៤

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧២ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ១៦០៥

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៣ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ១៦០៦

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦០៧

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦០៨

២៥-៦-២០០១ - អនុក្រឹត្យលេខ ២៧៦ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ១៦០៩

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១០

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៦១១

២៥-៦-២០០១ - អនុក្រឹត្យ លេខ ២៧៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៦១២

២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៦១៣

២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៤

២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៦១៦

២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៦១៧

២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៨
២៧-៦-២០០១ - អនុក្រឹត្យ លេខ ២៨៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៩
២៨-៦-២០០១ - អនុក្រឹត្យ លេខ ២៨៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៦២០
២៨-៦-២០០១ - អនុក្រឹត្យ លេខ ២៨៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៦២១
២៨-៦-២០០១ - អនុក្រឹត្យ លេខ ២៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦២២
២៨-៦-២០០១ - អនុក្រឹត្យ លេខ ២៨៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦២៣

## ២-ផែនការណែនាំ

២៥-៦-២០០១ - ផែនការណែនាំ លេខ ០៩ ផ.ក.ណ ស្តីពីការរៀបចំព្រះរាជពិធីបុណ្យខួបលើកទី៨ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ១៦២៥

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

២៦-៦-២០០១ -ប្រកាស លេខ ៤១៣ ឧរថ.ឧតស.ប្រក អនុញ្ញាតឱ្យអ្នកស្រី ញៀម ចន្ថា ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ "រ៉េនបូ" ១៦២៨
២៧-៦-២០០១ -ប្រកាស លេខ ៤១៧ ឧរថ.ឧតស.ប្រក អនុញ្ញាតឱ្យលោក ច័ន្ទ ចំរើន ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធ "ELVIS" ១៦៣០

### ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### ប្រកាស

២៧-៦-២០០១ - ប្រកាស លេខ ២៧០ ប្រក.កសក ស្តីពីការបង្កើត លេខាធិការដ្ឋានអចិន្ត្រៃយ៍ អប់រំ និងបណ្តុះបណ្តាលកសិកម្ម ១៦៣១

## ៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

### ប្រកាស


២៦-៦-២០០១ -ប្រកាស លេខ ៤៨៤ អយក.ប្រក ស្តីពីការកំណត់ខេត្ត-ក្រុង ដាច់ស្រយាល និងតំបន់ជួបការលំបាក ១៦៣៦


## ៤_ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

### សេចក្តីសំរេច


២៧-៦-២០០១ -សេចក្តីសំរេច លេខ ១៦៥ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទ ឈ្មោះ " សេរវេនដេយអាត់វេនទិស្ទត្រពាំងព្រាល " ស្ថិតនៅភូមិត្រពាំងព្រាល ឃុំតជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ១៦៤០

២៧-៦-២០០១ -សេចក្តីសំរេច លេខ ១៦៦ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទ ឈ្មោះ " សេវេនដេយអាត់វេនទិស្ទ គោកព្នៅ " ស្ថិតនៅភូមិគោកព្នៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ១៦៤២

២៧-៦-២០០១ -សេចក្តីសំរេច លេខ ១៦៧ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទ ឈ្មោះ " សេវេនដេយអាត់វេនទិស្ទស្រែប្រាំង " ស្ថិតនៅ ឃុំជើងទៀន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ១៦៤៣

២៧-៦-២០០១ -សេចក្តីសំរេច លេខ ១៦៨ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទ ឈ្មោះ " ពួកជំនុំព្រះគ្រិស្តភ្នំពេញ " ស្ថិតនៅភូមិ២ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ១៦៤៥

២៨-៦-២០០១ -សេចក្តីសំរេច លេខ ១៦៩ កធស.សរ អនុញ្ញាតឱ្យបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទ ឈ្មោះ " ពាំពេត " ស្ថិតនៅភូមិស្វាយគយ ឃុំពាំពេត ស្រុកស្វាយទាប ខេត្តស្វាយរៀង ១៦៤៦

# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ១_ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០៦០១/០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

៣៣

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង ដើម្បីជំរុញ និងការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីជំរុញនិងការពារទៅវិញទៅមកនូវការវិនិយោគ

**មាត្រា ១ ..**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង ដើម្បីជំរុញនិងការពារទៅវិញទៅមកនូវការវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០០ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយ ។

**មាត្រា ២ ..**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

-៚-

# ព្រះរាជក្រម នស/រកម/០៦០១/០៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

៙

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការជំរុញ និងការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យ ប្រជុំពេញអង្គលើកទី ៥ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

***

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការជំរុញនិងការការពារវិនិយោគ

**មាត្រា ១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលចុះហត្ថលេខានៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

**មាត្រា ២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

***

## ព្រះរាជក្រម នស/រកម/០៦០១/០៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

៙

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងលើអនុសញ្ញា ស្តីពីដំណោះស្រាយវិវាទពាក់ព័ន្ធទៅនឹងការវិនិយោគរវាងបណ្តារដ្ឋ ហើយនិងបុគ្គលនៃរដ្ឋដទៃ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីដំណោះស្រាយ វិវាទពាក់ព័ន្ធ ទៅនឹងការវិនិយោគរវាងបណ្តារដ្ឋ ហើយនិងបុគ្គលនៃរដ្ឋដទៃ

**មាត្រា ១ .-**

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីដំណោះស្រាយវិវាទពាក់ព័ន្ធទៅនឹងការវិនិយោគ រវាងបណ្តារដ្ឋ ហើយនិងបុគ្គលនៃរដ្ឋដទៃ ដែលបានចុះហត្ថលេខា នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

***

**ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

៚

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យលព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ

-យោងតាមសំណើ របស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១.-** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនិយកម្ម ជូនលោក **ហួង មេីងស៊ុន** (HUANG MING SHUN) សញ្ជាតិអូស្ត្រាលី កើតថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៥៣ នៅតៃណាន់ ប្រទេសចិន ។

**មាត្រា២ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើ របស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំងឯកឧត្តម បណ្ឌិត **សិរ កុសល** បច្ចុប្បន្នប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ជាអគ្គាធិការនៃអគ្គាធិការដ្ឋាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៣

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

៙៚

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សំណើ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** តែងតាំងឯកឧត្តម **ឃីម សារិទ្ធ** ជាទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក លឹម រស់

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

សូម

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សំណើ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា១** .- ត្រូវបានតែងតាំងឯកឧត្តម **ហ៊ុន ស៊ីថា** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកទំនាក់ទំនងការងារមូលដ្ឋាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រឹត្យ នស/រកត/០៦០១/២១៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

៩១៩

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សំណើ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា១.-** ត្រូវបានតម្លើងឋានន្តរសក្តិឯកឧត្តមឧត្តមសេនីយ៍ត្រី **ទៅ តុល** អត្តលេខ ០០១០៩៨ បច្ចុប្បន្នជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# II- រាជរដ្ឋាភិបាលកម្ពុជា

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៥៤ អនក្រ.បក

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

៙

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស//៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩ /១៩ ចុះថ្ងៃទិ ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការបែងចែកឥណទានចំណាយថវិកា ចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការផ្ទេរឥណទានថវិកា

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ...

## សំរេច

**មាត្រា១** .- ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១.៥០០លានរៀល ( មួយពាន់ប្រាំរយលានរៀលគត់) ពីជំពូក១០ (បៀវត្ស និងប្រាក់បំណាច់ )មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២** .- ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ទូទាត់បំណុលឯកសណ្ឋាន ឆ្នាំ ២០០០ សងឱ្យក្រុមហ៊ុន សោម សុផល ។

**មាត្រា៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យ លេខ ៥៥ អនក្រ.បក

## ស្តីពី

## ការផ្ទេរឥណទានថវិកា

៚

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស//៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩ /១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកា ចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១** .- ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ១.១០០លានរៀល (មួយពាន់មួយរយលានរៀលគត់) ពីជំពូក១០ (បៀវត្ស និងប្រាក់បំណាច់) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២** .- ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ទូទាត់បំណុលឯកសណ្ឋាន ឆ្នាំ ២០០០ សងឱ្យក្រុមហ៊ុន គូ ហ៊ូឡុង ។

**មាត្រា៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ៥៦ អនក្រ.បក

## ស្ដីពី

## ការផ្ទេរឥណទានថវិកា

១៧

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/១០៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស//៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩ /១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការបែងចែកឥណទានចំណាយថវិកា ចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការផ្ទេរឥណទានថវិកា

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១** .- ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ២.៣០០លានរៀល (ពីរពាន់បីរយលានរៀលគត់) ពីជំពូក១០ (បៀវត្ស និងប្រាក់បំណាច់ )មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២** .- ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បើកយុទ្ធនាការជំរឿនជន បរទេស ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ៥៧ អនក្រ.បក**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការ**

**ដឹកនាំការងារនៃកម្មវិធីសិលា**

៚

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តិពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ ២០០១

## សំរេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះជំនួសឱ្យអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ។

**មាត្រា២ .-**

អនុក្រឹត្យនេះកំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំរចនាសម្ព័ន្ធរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍បែបវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ហៅថា " កម្មវិធីសិលា " ដោយមានការចូលរួមអនុវត្តពីគណៈកម្មាធិការអភិវឌ្ឍន៍ជនបទគ្រប់លំដាប់ថ្នាក់ ។

**មាត្រា៣ .-**

គោលដៅចំបងនៃកម្មវិធីសិលា គឺការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ និងពង្រឹងអភិបាលកិច្ចមូលដ្ឋាន តាមរយៈការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។ ដើម្បីសំរេចគោលដៅនេះ កម្មវិធីសិលាត្រូវ :-

១-រៀបចំយន្តការនិងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនានា ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព ។

២-ផ្តល់ហិរញ្ញប្បទាន សំរាប់អនុវត្តកម្មវិធីវិនិយោគខេត្ត ដើម្បីឆ្លើយតបនឹងតំរូវការពិតប្រាកដរបស់មូលដ្ឋាន ។

៣-វាយតំលៃប្រសិទ្ធភាពនៃប្រព័ន្ធ វិមជ្ឈការ និងវិសហមជ្ឈការនានា ក្នុងការរួមចំណែកអនុវត្តន៍គោលដៅអភិវឌ្ឍន៍ប្រទេស និងចងក្រងបទពិសោធន៍ទាំងនេះ ដើម្បីផ្ដល់ជូនដល់ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលសំរាប់រៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានា សំរាប់អនុវត្តគោលនយោបាយនេះ ។

៤-បណ្ដុះបណ្ដាលធនធានមនុស្ស សំរាប់អនុវត្តយន្ដការ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌនៃកម្មវិធីសិលា ។

**មាត្រា៤ .-**

សមាសភាពគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមានដូចខាងក្រោម :

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥-អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៧-អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ៨-អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩-អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកែទំរង់រដ្ឋបាលសាធារណៈ | សមាជិក |
| ១០-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ | អគ្គលេខាធិការ |

ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមានសិទ្ធិសំរេចបំពេញបន្ថែមសមាជិករបស់គណៈកម្មាធិការនេះ ដោយយោងតាមសំណូមពរការងារនៃកម្មវិធីសិលា ។

**មាត្រា៥ .-**

បង្កើតក្រុមការងារសំរាប់ជាវេទិកាក្នុងការសំរបសំរួល និងការពង្រឹងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការក្នុងកម្មវិធីសិលា រវាងរាជរដ្ឋាភិបាល និងសហគមន៍អ្នកផ្ដល់ជំនួយ ។ ប្រធានគណៈកម្មា

ធិការដឹកនាំការងារនៃកម្មវិធីសិលា មានសិទ្ធិអញ្ជើញប្រធាន ឬតំណាងស្ថាប័ន និងអាជ្ញាធរដែនដី ព្រមទាំងភាគីផ្តល់ជំនួយនានាឱ្យ ចូលរួមប្រជុំក្នុងវេទិកានេះ ។

## ជំពូក ២

## ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា៦ .-**

គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលាមានភារកិច្ច :

១-ទទួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តន៍កម្មវិធីសិលា ដើម្បីធានាតំលាភាពនិងគុណនេយ្យភាពក្នុងការប្រើប្រាស់ប្រភពធនធានដែលមាន ។

២-ពិនិត្យនិងអនុម័តផែនការសិលា និងការវិភាជន៍ធនធានប្រចាំឆ្នាំ ។

៣-សំរបសំរួលការអនុវត្តន៍កម្មវិធីសិលា រវាងបណ្តាក្រសួងជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងខេត្តអនុវត្តកម្មវិធីសិលា ។

៤-សំរួលការពិភាក្សាគោលនយោបាយ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការខាងផ្នែកផែនការ ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចការអភិវឌ្ឍន៍មូលដ្ឋានក្នុងក្របខ័ណ្ឌ នៃកម្មវិធីសិលា ។

៥-តាមដាន ត្រួតពិនិត្យ និងវាយតំលៃប្រសិទ្ធភាពនៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងខេត្តអនុវត្តកម្មវិធីសិលា និងចងក្រងបទពិសោធន៍ជូនរាជរដ្ឋាភិបាល សំរាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយជាតិ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។

៦-ពិនិត្យ និងសំរេចលើលទ្ធផលនៃសវនកម្ម ស្តីពីការគ្រប់គ្រងប្រព័ន្ធគណនេយ្យ ដើម្បីធានាឱ្យបានស្របនឹងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។

៧-រាយការណ៍រៀងរាល់៦ខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តន៍កម្មវិធីសិលា ជូនរាជរដ្ឋាភិបាល និងភាគីផ្តល់ជំនួយ ព្រមទាំងភាគីពាក់ព័ន្ធនានា ។

៨-បណ្តុះបណ្តាលធានធានមនុស្ស សំរាប់អនុវត្តការងារផែនការ ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ។

៩-សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយរាជរដ្ឋាភិបាល ក្នុងការគៀងគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់កម្មវិធីសិលា ព្រមទាំងអាចចុះហត្ថលេខាជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលជំនួយដែលសហគមន៍អន្តរជាតិផ្តល់សំរាប់គាំទ្រកម្មវិធីសិលា ។

**មាត្រា៧ .-**

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា មានអគ្គលេខាធិការដ្ឋាន ដែលមានទិស្នាក់ការនៅទិស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

អគ្គលេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម :-

១-សំរបសំរួលដំណើរប្រព្រឹត្តទៅ របស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានជាអាទិ៍ ការរៀបចំផែនការការងារប្រចាំឆ្នាំ ចាត់ចែងនិងរៀបចំកិច្ចប្រជុំនិងរបៀបវារៈនៃអង្គប្រជុំគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា ។

២-គ្រប់គ្រងកិច្ចប្រតិបត្តិការនៃកម្មវិធិសិលា ។

៣ រៀបចំរបាយការណ៍រៀងរាល់ ៦ខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តន៍កម្មវិធីសិលា ។

៤-វាយតំលៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខ័ណ្ឌកម្មវិធិសិលា ព្រមទាំងផ្សព្វផ្សាយជូនបណ្តាភាគីពាក់ព័ន្ធ ។

៥-សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា រវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលាជាមួយនិងស្ថាប័នជាតិ ដទៃទៀត និងរវាងថ្នាក់ជាតិ និងថ្នាក់ខេត្តអនុវត្តកម្មវិធិសិលា ។

៦-ជួយរៀបចំ និងពិនិត្យសេចក្តីព្រាងកិច្ចព្រមព្រៀងហិរញ្ញប្បទានសំរាប់គាំទ្រកម្មវិធីសិលា រវាងសហគមន៍អ្នកផ្តល់ជំនួយ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៧-ចុះហត្ថលេខាលើលិខិតអញ្ជើញប្រជុំបច្ចេកទេសជាមួយក្រុមការងារតាមក្រសួង និងដឹកនាំកិច្ចប្រជុំនេះ ។

៨-គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទានជាតិនិងអន្តរជាតិ ។

៩-គ្រប់គ្រង ប្រព័ន្ធគណនេយ្យនិងធ្វើសវនកម្មឱ្យបានសមស្របនឹងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។

១០-បំពេញការងារផ្សេងៗទៀត តាមការប្រគល់សិទ្ធិរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធិសិលា ។

**មាត្រា ៨ .-**

អគ្គលេខាធិការដ្ឋាននេះ ត្រូវបានដឹកនាំដោយអគ្គលេខាធិការនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា អមដោយអគ្គលេខាធិការរង និងជំនួយការមួយចំនួនតាមការចាំបាច់ ។

**មាត្រា ៩ .-** អគ្គលេខាធិការដ្ឋាននៃកម្មវិធីសិលាចែកចេញជា ២ ផ្នែក :

១-ផ្នែកគ្រប់គ្រងកិច្ចប្រតិបត្តិការនៃកម្មវិធី

២-ផ្នែកត្រួតពិនិត្យ និងវាយតំលៃការអនុវត្តន៍គោលនយោបាយ

ផ្នែកនីមួយៗរបស់លេខាធិការដ្ឋានមានឋានៈស្មើនាយកដ្ឋាន និងបំពេញការងារជាជំនួយការរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។ តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗចំណុះអគ្គលេខាធិការដ្ឋាន នឹងត្រូវកំណត់ដោយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

**មាត្រា ១០ .-**

មន្ត្រីបំរើការងារក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា គឺជាមន្ត្រីក្របខ័ណ្ឌដែលខ្ចីពីក្រសួង និងស្ថាប័ននានា ឬជាបុគ្គលិកដែលបំពេញការងារតាមកិច្ចសន្យា ។

**មាត្រា ១១ .-**

បង្កើតក្រុមការងារសិលានៅតាមក្រសួង ដើម្បីសំរបសំរួលនិងជួយការងារទាំងឡាយរបស់សមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

ក្រុមការងារសិលាតាមក្រសួងទាំងនេះ មានភារកិច្ចរួមដូចខាងក្រោម :-

១-ជាសមភាគីការងាររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ។

២-រៀបចំផែនការការងាររបស់ក្រសួងដែលទាក់ទងទៅនឹងការអនុវត្តន៍កម្មវិធីសិលា ។

៣-ទំនាក់ទំនង និងគាំទ្រមន្ទីរខេត្តរបណ្តោយរបស់ខ្លួននៅថ្នាក់ខេត្ត ឱ្យអនុវត្តកម្មវិធីសិលាប្រកបមានប្រសិទ្ធភាព និងដោះស្រាយរាល់បញ្ហានានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៤-ពិនិត្យផែនការ និងរបាយការណ៍អនុវត្ត ដែលទទួលបានពីមន្ទីរខ្សែបណ្តោយក្រសួង ។

៥-សំរបសំរួល និងសហការជាមួយក្រសួងផ្សេងៗ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍កម្មវិធីសិលា ។

៦-ផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈកម្មវិធីសិលានៅក្នុងក្រសួង និងផ្តល់អនុសាសន៍ទាំងឡាយដល់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា សំរាប់ពិនិត្យនិងពិចារណា ដើម្បីដាក់ជូនគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាអនុម័ត ។

៧-ពិនិត្យតាមដានការអនុវត្តន៍កម្មវិធីសិលា តាមវិស័យរបស់ខ្លួននៅថ្នាក់ខេត្ត និងផ្តល់របាយការណ៍ជូនសមាជិកនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

ភារកិច្ចដោយឡែកនៃក្រុមការងារសិលានៅតាមក្រសួងនីមួយៗ នឹងត្រូវកំណត់ដោយសមាជិកនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលារបស់សាមីក្រសួង ដោយយោងតាមឯកសារកម្មវិធីសិលាឆ្នាំ ២០០១-២០០៥ ។

**មាត្រា ១២ .-**

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង (គ.អ.ជ.ខ) ដែលមានអភិបាលខេត្ត-ក្រុង ជាប្រធាន ត្រូវទទួលខុសត្រូវ ក្នុងការគ្រប់គ្រងកម្មវិធីសិលា នៅថ្នាក់ខេត្ត ។ បន្ថែមលើភារកិច្ចដែលមានចែងក្នុងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០២ សសរ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ត្រូវមានភារកិច្ចដូចខាងក្រោម :-

១-ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ខេត្ត ។

២-ពិនិត្យ និងផ្តល់ចំណាប់ឯកភាពលើផែនការវិនិយោគសិលា ហើយស្នើមកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីអនុម័ត ។

៣-អនុម័តការវិភាជន៍មូលនិធិវិនិយោគសិលា ឱ្យស៊ីសង្វាក់នឹងយុទ្ធសាស្ត្រនៃកម្មវិធីសិលា ។

៤-ជ្រើសរើសតំបន់គោលដៅ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និងលទ្ធភាពធនធានដែលមាន ។

៥-ជួយជំរុញ និងគាំទ្រកិច្ចសហការប្រកបដោយប្រសិទ្ធភាព រវាងស្ថាប័ននានារបស់រាជរដ្ឋាភិបាលផ្នែកឯកជន សង្គមស៊ីវិល និងភ្នាក់ងារអភិវឌ្ឍន៍ជាតិនានា ក្នុងការរៀបចំផែនការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ជនបទរបស់ខេត្ត ។

៦-ចាត់ចែង និងរិះរកវិធានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលបានទទួលពីគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

៧-ពិនិត្យ និងឯកភាពលើរបាយការណ៍ ស្តីពីការអនុវត្តន៍ផែនការវិនិយោគសិលារបស់ខេត្ត ហើយផ្ញើមកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

**មាត្រា ១៣ .-**

ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា ១២ ខាងលើ គ.អ.ជ.ខ ត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាសភាព ភារកិច្ច និងរចនាសម្ព័ន្ធ តាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាថ្នាក់ជាតិ សំរាប់គ្រប់គ្រងការអនុវត្តន៍ផែនការវិនិយោគសិលាប្រចាំឆ្នាំរបស់ខេត្ត ។

**មាត្រា ១៤ .-**

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក សំរាប់រាលលិខិតផ្លូវការរបស់ខ្លួន ។

## ជំពូកទី ៣

## មូលនីធិ

**មាត្រា ១៥ .-**

ប្រភពនៃមូលនីធិសំរាប់អនុវត្តកម្មវិធីសិលា មានជាអាទិ៍ :-

១-ជំនួយឥតសំណង និងឥណទានពីអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី

២-ហិរញ្ញប្បទានពីថវិការដ្ឋ

៣-អំណោយពីសប្បុរសជននានា និងអង្គការក្រៅរដ្ឋាភិបាល ។

**មាត្រា ១៦ .-**

មូលនិធិដែលគៀងគរបានពីប្រភពដូចមានចែងក្នុងមាត្រា១៥ខាងលើ ត្រូវបានប្រើប្រាស់សំរាប់កិច្ចអភិវឌ្ឍន៍ជនបទតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ហៅថា " មូលនិធិអភិវឌ្ឍន៍វិមជ្ឈការ និងវិសហមជ្ឈការ " ហើយត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំបទប្បញ្ញត្តិ និងនីតិវិធីសំរាប់កិច្ចដំណើរការនៃមូលនិធិនេះ ។

**មាត្រា ១៧ .-**

ក្នុងការគ្រប់គ្រងមូលនីធិនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវអនុវត្តកិច្ចការដូចតទៅ :-

១-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគៀងគរធនធានក្នុងស្រុកនិងក្រៅប្រទេស សំរាប់កម្មវិធីសិលា ។

២-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានការអនុវត្តន៍កិច្ចព្រមព្រៀងហិរញ្ញប្បទាន ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ព្រមទាំងរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្ញើជូនរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ តាមកាលកំណត់ដែលបានឯកភាពគ្នា ។

៣-ពិនិត្យតាមដានការផ្ទេរមូលនិធិអភិវឌ្ឍន៍វិមជ្ឈការ និងវិសហមជ្ឈការឱ្យទៅគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ដែលអនុវត្តកម្មវិធីសិលា ។

៤-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើសវនកម្មគណនីរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៨ .-**

អនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សិលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៤ និង អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ២៧០ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

៚ ០ ៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តិពិការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ/បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** .- តែងតាំងលោក **ស៊ ចន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានផែនការ ជាប្រធាននាយកដ្ឋានផែនការ នៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ២៧១ អនក្រ.តត

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

៙៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពិការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ/បក ចុះថ្ងៃទិ ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពិការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១** .- តែងតាំងលោក **ឆាយ សុខន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុលជាប្រធាននាយកដ្ឋាន ច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមិខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ២៧២ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

៙៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

## សំរេច

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនអង្គការអន្តរជាតិ សប្បុរសជន ០៤រូប ដែលបានបរិច្ចាគថវិកា ជួយកសាងអាគារសិក្សា ១៤ខ្នង មាន ៤៤ បន្ទប់ នៅសាលាបឋមសិក្សាថ្លុលបែក ឃុំត្រពាំងឫស្សី សាលាគុហាព្រះធាតុ ឃុំស្រឡៅ សាលាក្រសាំងជ័យ សាលាចតុលោក ឃុំបារាយណ៍ សាលាឥន្ទកុមារ ឃុំកំពង់ស្វាយ សាលាបណ្តុះបណ្តាលវិជ្ជា ឃុំសូយោង និងអនុវិទ្យាល័យទួលក្បិល នៅក្នុងស្រុកសន្ទុក ស្រុកបារាយណ៍ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **អ៊ឹក សួន** ព្រះចៅអធិការវត្តបុទុមវតី បច្ច័យចំនួន ១០.០០០ USD

២-អ្នកស្រី **ស្រ៊ី ចាន់ផល្លារ៉ា** ប្រធានអង្គការកម្ពុជា ដើម្បីអភិវឌ្ឍន៍ និងលើកស្ទួយសិទ្ធិ ទឹកប្រាក់ចំនួន ៤៩.១១៤ USD

៣-លោកតា **តាំង ឈឹម** និងលោកយាយ **ខ្សៃ ហ៊ាង** ទឹកប្រាក់ចំនួន ១៩.០០០ USD

៤-លោក **ស គិន** និងអ្នកស្រី **ជិន ទឿន** ទឹកប្រាក់ចំនួន ១៣.០០០ USD

៥-អង្គការយុវជនបំពេញបេសកកម្មនៅកម្ពុជា ( YWAM ) សាងសង់អាគារសិក្សា ចំនួន០៤ខ្នង មាន២០បន្ទប់ ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៣ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ជួន គីឧថាន** សប្បុជនខ្មែរ នៅសហរដ្ឋអាមេរិក ដែលបានជួយកសាងកុដិ ០១ខ្នង នៅក្នុងវត្ត **នន្ទីច័ន** ហៅវត្តស៊ីង ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់ផ្ទាល់ខ្លួនចំនួន ១៧.៦៨០ USD ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៤ អនក្រ.តត**

**ស្ដីពី**

**ការជូនមេដាយស្ថាបនាជាតិ**

៙

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **អ៊ីវ ម៉ូដដេហ្គុត** (IVES MEAUDES DES GOUTTES) អគ្គនាយកអង្គការកុមារមេត្តា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងអាគារសិក្សា ០១ខ្នង មាន០៣បន្ទប់ និងបំពាក់សំភារៈសិក្សា មានតុ កៅអីសិស្ស តុគ្រូ ក្ដារខៀនគ្រប់បន្ទប់ នៅវិទ្យាល័យសម្ដេចឪ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ចំនួន ១៥.000 USD ។

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៥ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣រូប នៃអង្គការ ការីតាសដែលបានខិតខំអំពាវនាវ រកជំនួយមនុស្សធម៌ មកកសាងមណ្ឌលសុខភាព គោកដូង ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **ចឹស្សេម អេមីល ដេសតួមបែស**

២-លោក **ម៉ារីយ៉ា ទិចធំ**

៣-លោកស្រី **ម៉េរណា ដៃត្បាល្លិស**

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៦ អនក្រ.តត**

**ស្ដីពី**

**ការជូនមេដាយស្ថាបនាជាតិ**

៣៧

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ក្នុងការជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា និងវិស័យអប់រំ នៅក្នុងឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

១-ព្រះតេជគុណ **ម៉ក់ ព្រឿង** ចៅអធិការវត្តបុទុមសុរិយាកសាងផ្លូវថ្នល់ ស្រះទឹក កុដិ ព្រះវិហារ សរុប បច្ច័យ ចំនួន ៤១.២៧៥.០០០៛ ។

២-ឯកឧត្តម បណ្ឌិត **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន កសាងអាគារសិក្សា ០២ខ្នង សាលាពុទ្ធិកបឋមសិក្សា ជួសជុលកែលំអផ្លូវលំ ជីកអណ្តូងទឹក ស្រះទឹក សរុបទឹកប្រាក់ ចំនួន ២៣.០០០ USD ។

៣-លោក **អូលដី** ប្រធានអង្គការស្ថានកម្ពុជា-ហូឡង់ កសាងអាគារសិក្សា ០១ខ្នងក្នុងអនុវិទ្យាល័យបុទុមសុរិយា និងសាលាបឋមសិក្សា ០២ខ្នង សរុបទឹកប្រាក់ ចំនួន ២១.០០០ USD ។

៤-លោក **ខួន ផាន** តំណាងអង្គការស្ថានកម្ពុជា-ហូឡង់ កសាងអាគារសិក្សា ០១ខ្នង ក្នុងអនុវិទ្យាល័យបុទុមសុរិយា ធ្វើស្ពាន សង់ផ្ទះជូន ប្រជាជន ១៨ខ្នង សរុបទឹកប្រាក់ ចំនួន ១២.០០០ USD ។

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យ លេខ ២៧៧ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន ( AEON FANTASY Co.Ltd ប្រទេសជប៉ុន ដែលបានជួយសាងសង់អាគារសិក្សា ០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សាទួលទទឹង ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចំណាយទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៨ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយសហមេត្រី**

៚

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ " **សេនា** " ជូនលោក ( Nils BaCkstrom ) ទីប្រឹក្សាផ្នែកគ្រប់គ្រងការងារចែកផ្សាយសៀវភៅសិក្សា ស្ថាប័នជំនួញ និងសហប្រធានក្រុមអ្នកពិគ្រោះការអន្តរជាតិ ដែលបានមកបំពេញបេសកកម្ម ក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍សៀវភៅសិក្សា សំរាប់អប់រំមូលដ្ឋាន ចាប់តាំងពីឆ្នាំ ១៩៩៧ ហើយបានរួមចំណែកយ៉ាងសកម្ម ស្មោះត្រង់ក្នុងការផ្ទេរចំណេះដឹង និងមានការទំនាក់ទំនងល្អនៃអន្តរវិញ្ញូធម៌ ពីសំណាក់ក្រុមអ្នកពិគ្រោះអន្តរជាតិ ប្រចាំអង្គភាពអនុវត្តគំរោង ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៧៩ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយសហមេត្រី**

៙

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក **វីរ៉ាសាក់ ឡមវង់** (Colonel WEERASAK LOMWONG )សេនានុពន្ធថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការលើកស្ទួយនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការយោធាថៃ ជាមួយកម្ពុជា ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

ភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យ លេខ ២៨០ អនក្រ.តត

## ស្តីពី

## ការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយការងារ** ថ្នាក់មាសជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ទោ **គេត សាវឿន** អគ្គនាយករង នៃអគ្គនាយកដ្ឋាននគរបាលជាតិ

២-លោកឧត្តមសេនីយ៍ទោ **គីម សំណាង** អគ្គនាយករង នៃអគ្គនាយកដ្ឋាននគរបាលជាតិ

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទិស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

បានចុះហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៨១ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ហាបនាជាតិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងស្ពានមួយកន្លែង និងផ្លូវមួយខ្សែ នៅព្រំប្រទល់ឃុំព្រះនិពាន្ទ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :

**ក.មេដាយមាសស្ថាបនាជាតិ : ចំនួន០២រូប**

| | | |
|---|---|---|
| ១-ឧបាសក | **ភាំង ណាំហេង** | ថវិកាចំនួន ១០.២០០ USD |
| ២-លោកជំទាវ **អ៊ុយ ឡេង** | | ថវិកាចំនួន ១០.៣៥០ USD |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ : ចំនួន០២រូប**

| | | |
|---|---|---|
| ១-ឧបាសិកា | **ស្រេង ហេងជូ** | ថវិកាចំនួន ៥.០២៥ USD |
| ២-លោកស្រី | **សុខ ម៉ូយ** | ថវិកាចំនួន ៥.២៣០ USD |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យ លេខ ២៨២ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

៚៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយមុនិសារាភ័ណ្ឌ (ថ្នាក់សេនា)** ប្រគេនជូនព្រះសង្ឃ អាចារ្យវត្ត ចំនួន ០៣រូប ដែលបានខិតខំប្រឹងប្រែងយកអស់កំលាំងកាយពល ចូលរួមកសាង ព្រះវិហារ វត្តទួលសាលា ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមជូនខាងក្រោម :

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **អ៊ី ខុន** | អនុគណស្តិទិស្រុកកណ្តាលស្ទឹង |
| ២-ព្រះតេជគុណ | **យូ ជាន់** | ព្រះចៅអធិការវត្តទួលសាលា |
| ៣-លោកតា | **គា ថ្វីខ** | គណៈកម្មការវត្តទួលសាលា |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងធម្មការនិងកិច្ចការសាសនា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ២៨៣ អនក្រ.តត

## ស្តីពី

## ការផ្តល់មេដាយការងារ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយមាសការងារ** ជូនអភិបាលស្រុក និងអភិបាលរងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការដឹកនាំការងារនៅក្នុងមូលដ្ឋាន ដូចមានរាយនាមខាងក្រោម :

១-លោក **ប៊ុន ថេង** អភិបាលស្រុកកណ្តាលស្ទឹង

២-លោក **ប៊ូ ណារ៉េត** អភិបាលរងស្រុកកណ្តាលស្ទឹង

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

-៚-

# អនុក្រឹត្យ លេខ ២៨៤ អនក្រ.តត

## ស្ដីពី

## ការជូនមេដាយស្ថាបនាជាតិ

៛

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកណ្ដាល

## សម្រេច

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ ស្ថិតក្នុងវត្តទួលសាលា ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដូចមាន រាយនាមជូនខាងក្រោម :

**ក.-មេដាយមាសស្ថាបនាជាតិ : ចំនួន០២រូប**

១-លោកយាយ មហាឧបាសិកា **ម៊ុន សៀវលី** ថវិកាចំនួន ១៧.២០០ USD

២-លោកជំទាវ **ម៊ុន សុថា** ថវិកាចំនួន ១៥.០០០ USD

**ខ.-មេដាយប្រាក់ស្ថាបនាជាតិ : ចំនួន០១រូប**

១-លោក **ខួន ហុង** ថវិកាចំនួន ៥.០០០ USD

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៨៥ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

៚

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ចំនួន ០៧រូប ដែល បានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ ស្ថិតក្នុងវត្តទួលសាលា ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយនាមជូនខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិ : ចំនួន០៦រូប**

១-ឧបាសិកា **ឈា ណៃ** ថវិកាចំនួន ១២.០០០ USD

២-លោកជំទាវ **ប៊ុន សាមឡេន** ថវិកាចំនួន ១១.០០០ USD

៣-ឯកឧត្តម **តាន់ បញ្ញាវុធ** ថវិកាចំនួន ១១.០០០ USD

៤-ឯកឧត្តម **ហ៊ីង ប៊ុនហៀង** និងលោកជំទាវ ថវិកាចំនួន ១០.១០០ USD

៥-ឯកឧត្តម **ចក់ ឡេង** និងលោកជំទាវ ថវិកាចំនួន ១០.០៥៨ USD

៦-លោក **ពៅ សុតារាត** និងលោកស្រី ថវិកាចំនួន ១០.០០០ USD

**ខ. មេដាយប្រាក់ស្ថាបនាជាតិ : ចំនួន០១រូប**

១-លោក **ឆ្វំ ហេង** និងលោកស្រី ថវិកាចំនួន ៥.១០០ USD

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៨៦ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយសហមេត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ "**អស្សឫទ្ធិ**" ជូនលោកវរសេនីយ៍ឯក **ត្រាន់ ង៉ុក ក្វេ** (Colonel TRAN NGOC QUE) សេនានុពន្ធវៀតណាម ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយនូវចំណងមិត្តភាព នឹងកិច្ចសហប្រតិបត្តិការរវាងកងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាម និងកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៨៧ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយសហមេត្រី**

**៙**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា១.-** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ "**អស្សឫទ្ធិ**" ជូនលោកវរសេនីយ៍ឯក **ហ្សង់ លូីវ៉ែងត្រឺប៊ែរ** (Colonel JEAN-LOUIS WINTREBERT) សេនានុពន្ធបារាំង ដែលមានស្នាដៃល្អក្នុងការលើកស្ទួយនូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងកងទ័ពសាធារណរដ្ឋបារាំង និងកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យ លេខ ២៨៨ អនក្រ.តត**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសាធារណៈការនិងដឹកជញ្ជូន

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

**សំរេច**

**មាត្រា១.-** ត្រូវបានតែងតាំងលោក **ឌុំ សោ** ជាទីប្រឹក្សារបស់ឯកឧត្តម **ឃី តាំងលឹម** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ២៨៩ អនក្រ.តត**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

៙

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសាធារណៈការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសាធារណៈការនិងដឹកជញ្ជូន

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសាធាណការ និងដឹកជញ្ជូន

**សំរេច**

**មាត្រា១.-** ត្រូវបានតែងតាំងលោក **ស៊ឹម ស៊ុខ្សេង** ជាបេសកជនរបស់ឯកឧត្តម **ឃី តាំងលឹម** រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## ២. សេចក្តីណែនាំ

### សេចក្តីណែនាំ លេខ ០៩ ជកណ

### ស្តីពី

### ការរៀបចំព្រះរាជពិធីបុណ្យខួបលើកទី៨ នៃការគ្រងរាជសម្បត្តិជាថ្មីរបស់ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងពិធីបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ

៚

• ថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០០១ គឺជាទិវាបុណ្យខួបលើកទី៨ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រជាទីគោរពសក្ការៈ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ គឺថ្ងៃនេះហើយដែលប្រជារាស្ត្រខ្មែរគ្រប់រូប បានសំដែងឆន្ទៈ និងមនោសញ្ចេតនារបស់ខ្លួនសប្បាយរីករាយយ៉ាងជ្រាលជ្រៅបំផុតចំពោះ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ដែលសព្វព្រះរាជហឫទ័យ ទ្រង់គ្រងរាជសម្បត្តិជាថ្មីឡើងវិញ ដើម្បីបានគង់នៅជាម្លប់ដ៏សុខក្សេមក្សាន្តត្រជាក់ត្រជុំរបស់មាតុភូមិអង្គរ និងប្រជារាស្ត្រខ្មែរ ជាកូន ជាចៅ ចៅទួតរបស់ព្រះអង្គ ។

• ថ្ងៃទី២៤ ខែ កញ្ញា នេះដែរ ក៏ជាថ្ងៃដែលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូលប្រកបដោយខ្លឹមសារយ៉ាងជ្រាលជ្រៅលើគ្រប់វិស័យ ដែលសភាធម្មនុញ្ញបានអនុម័ត ត្រូវបានប្រកាសដ៏មហោឡារិកបើកឱ្យប្រើប្រាស់ជាផ្លូវការ ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

• ឆ្នាំនេះពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ នឹងប្រព្រឹត្តទៅពីថ្ងៃ ១រោជ ដល់១៥រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី៣ ដល់ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០១ តាមប្រពៃណីព្រះពុទ្ធសាសនា ។ បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិដ៏សំខាន់របស់ពុទ្ធសាសនិកខ្មែរគ្រប់រូប ។ ពិធិនេះប្រារព្ធឡើងដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខ័ន្ធនៃអ្នកមានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ បុព្វបុរសជាតិជាដើម និងបងប្អូនជនរួមជាតិទាំងឡាយដែលបានលាលោកនេះទៅកាន់លោកខាងមុខ ។ ម្យ៉ាងទៀតពិធីនេះជាឱកាសបានជួបជុំឪពុកម្តាយ បងប្អូន ញាតិមិត្ត សាច់សាលោហិតដែលរស់នៅទីផ្សេងៗគ្នា និងអាចស្វែងយល់បានពីសុខទុក្ខ ការងាយស្រួល និងការលំបាកក្នុងជីវភាពរស់នៅទៅវិញទៅមក ព្រមទាំងបង្កើនបាននូវសាមគ្គីភាពដ៏ទូលំទូលាយផង ។

ដើម្បីសំដែងនូវកត្តញ្ញូតាធម៌ ចំពោះព្រះមហាករុណាធិគុណ និងព្រហ្មវិហារធម៌ ថ្វាយព្រះពរសព្ទសាធុការបវរមហាប្រសើរ និងថ្វាយព្រះរាជកុសលចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេច ព្រះរាជអគ្គមហេសី** ជាទីគោរពសក្ការៈ សូមទ្រង់គង់នៅ ក្នុងព្រះបរមសិរី រាជសម្បត្តិ យូរអង្វែង សំដែងនូវអំណរសាទរ គោរពដោយស្មោះត្រង់ ចំពោះរដ្ឋធម្មនុញ្ញ និងដើម្បីបើកឱកាសជូនពុទ្ធបរិស័ទ បំពេញកុសលតាមសទ្ធាជ្រះថ្លា និងប្រពៃណីជាតិ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំអនុវត្តដូចតទៅ :-

១-គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតុបតែងលំអរចនាដោយភ្លើងពណ៌ តាំងព្រះឆាយាលក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ដោយមានពាក្យស្លោក ថ្វាយព្រះពរ និងសារលិខិតថ្វាយព្រះពរ តាមទីស្នាក់ការរបស់ខ្លួន ព្រមទាំងបំផុសប្រជារាស្ត្រឱ្យដោតទង់ជាតិ គ្រប់គេហដ្ឋាន និងបដាអបអរសាទរ ។

២-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យទាំងបីខាងលើ ឱ្យបានសមស្របតាមលទ្ធភាពជាក់ស្តែងក្នុងក្របខ័ណ្ឌខេត្ត-ក្រុងនីមួយៗ ដោយមានព្រះសង្ឃក្នុងក្របខ័ណ្ឌខេត្ត-ក្រុង ថ្នាក់ដឹកនាំខេត្ត-ក្រុង មន្ត្រីរាជការនៃមន្ទីរនានា ជុំវិញខេត្ត-ក្រុង ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ប្រជាពលរដ្ឋចូលរួមឱ្យបានឧឡារិក ព្រមទាំងមានកម្មវិធីចុះសួរសុខទុក្ខតាមមន្ទីរពេទ្យ មណ្ឌលកុមារកំព្រាផង ។

៣-ក្រសួងពត៌មាន ត្រូវណែនាំចាត់ឱ្យបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ ឯកជនតាមដានយកពត៌មាន ធ្វើការផលិតផ្សព្វផ្សាយ ឃោសនាអប់រំឱ្យបានទូលាយនូវសកម្មភាពជាប្រពៃណីទំនៀមទំលាប់ជាតិ ។

៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ត្រីវប្បធម៌ខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈបុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវា ជាប្រវត្តិសាស្ត្រនេះ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០០១ ព្រមទាំងត្រូវបំផុសចលនាឱ្យពុទ្ធបរិស័ទរក្សាបានប្រពៃណីទំនៀមទំលាប់ដែលល្អៗ ដើម្បីឱ្យយុវជនជំនាន់ក្រោយបន្តវេនថែរក្សាឱ្យបានគង់វង្ស ។

៥-ក្រសួងធម្មការ និងសាសនា ត្រូវធ្វើការណែនាំលំអិតដល់មន្ទីរធម្មការខេត្ត-ក្រុង ឱ្យយកចិត្តទុកដាក់បង្គលក្ខណៈឱ្យបានល្អប្រសើរប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ ប្រារព្ធពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌ តាមប្រពៃណីទំនៀមទំលាប់ ដោយសទ្ធាជ្រះថ្លា តាមពេលវេលាកំណត់ ។

៦-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវណែនាំ ដល់អង្គភាពក្រោមឱវាទឱ្យសហការ ការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម បំរើការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិ ជាថ្មីរបស់ព្រះមហា

ក្សត្រ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ ព្រមទាំងបង្គលក្ខណៈ ប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទបំពេញកុសលក្នុងពិធីកាន់បិណ្ឌ ភ្ជុំបិណ្ឌ តាមវត្តអារាមនានា តាមសំណូមពរ ធានាសេចក្តីសុខក្សេមក្សាន្ត និងសប្បាយរីករាយ ។

៧-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល អង្គការមនុស្សធម៌ ក្រុមហ៊ុន ឯកជនជួយឧបត្ថម្ភជាថវិកា សម្ភារៈ គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខដល់អ្នករបួស មានជម្ងឺកំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យគ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនាអាណិតស្រឡាញ់រាប់អាន លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តពេញលេញនូវផែនការណែនាំនេះ ឱ្យបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមប្រពៃណីរបស់ជាតិយើង ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

~

## ពាក្យស្លោកសំរាប់ប្រើប្រាស់

## ក្នុងព្រះរាជពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មី នៃព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ

~

១- អបអរសាទរខួបលើកទី ៨ នៃព្រះរាជពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ។

២- អបអរសាទរខួបលើកទី ៨ ទិវាប្រកាសរដ្ឋធម្មនុញ្ញ ។

៣- អបអរសាទរបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិ ។

៤- ជយោ ! លិទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា ។

៥- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ ។

៦- ជយោ ! ព្រះរាជាណាចក្រកម្ពុជា ។

៧- ជាតិ សាសនា ព្រះមហាក្សត្រ ។

៨- សូមថ្វាយព្រះពរសម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៩- ប្តេជ្ញាជំរុញការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានសំរេចជោគជ័យ ។

១០- ពលរដ្ឋគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

១១- ការពារខាប់ខាត រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ៤១៣ ឧរថ.ឧតស.ប្រក**

~~~

## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និងសិប្បកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
~~~

-យោងពាក្យស្នើសុំបើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ " រ៉េនបូ " របស់អ្នកស្រី ញៀម ចន្ថា ចុះថ្ងៃទី០៨-០២-១៩៩៩ ។

-បានឃើញការយល់ព្រមលេខ ១១៥៨ លស.ស ចុះថ្ងៃទី ១១-៦-២០០១ របស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យអ្នកស្រី **ញៀម ចន្ថា** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៣៧៦៩៦ ភ.៣ ចុះថ្ងៃទី១៦-០១-១៩៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៩២ ផ្លូវលេខ៤៧០ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ " រ៉េនបូ " នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២** : អ្នកស្រី **ញៀម ចន្ថា** ត្រូវមកចុះបញ្ជីផលិតផល និងយកគំរូផលិតផលទឹកបរិសុទ្ធរបស់ខ្លួនមកពិនិត្យគុណភាព នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុននឹងចរាចរនៅលើទីផ្សារ ។

**ប្រការ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

**ប្រការ៤** : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងអ្នកស្រី **ញៀម ចន្ថា** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ៥** : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ស៊ុយ សែម**

***

ភ្នំពេញ,ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ៤១៧ ឧរថ.ឧតស.ប្រក**

~~~

**រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និងសិប្បកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងពាក្យស្នើសុំបើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ " ELVIS " របស់លោក **ច័ន្ទ ចំរើន** ចុះថ្ងៃទី២២-៣-០១ ។

-បានឃើញការយល់ព្រមលេខ ១២៦១ លស.ស ចុះថ្ងៃទី ១៩-៦-០១ របស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឱ្យលោក **ច័ន្ទ ចំរើន** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣០២៥៨៦ ភ.ព ចុះថ្ងៃទី១៦-០១-១៩៨១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៣១ ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ " ELVIS " នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២ :** លោក **ច័ន្ទ ចំរើន** ត្រូវមកចុះបញ្ជីផលិតផល និងយកគំរូផលិតផលទឹកបរិសុទ្ធរបស់ខ្លួនមកពិនិត្យគុណភាព នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុននឹងចរាចរនៅលើទីផ្សារ ។
~~~

**ប្រការ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

**ប្រការ៤** : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និង លោក **ចំនួ ចំរើន** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

**ប្រការ៥** : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ស៊ុយ សែម**

***

## ២~ ទីស្តីការរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១

### ប្រកាសលេខ ២៧០ ប្រក.កសក

### ស្តីពី

### ការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍អប់រំ និងបណ្តុះបណ្តាលកសិកម្ម

~~~

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
~~~

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសលេខ ១០៣៦ ប្រក.កសក ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការឧត្តមសិក្សាកសិកម្ម

-បានឃើញផែនការសកម្មភាពជាតិឧត្តមសិក្សាកសិកម្ម ខែ មេសា ឆ្នាំ ១៩៩៩

-យោងតាមការចាំបាច់របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ប្រការ ១ :** បង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ មានឈ្មោះថា " លេខាធិការដ្ឋានអចិន្ត្រៃយ៍អប់រំ និងបណ្តុះបណ្តាលកសិកម្ម " ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពី អនុប្រធានគណៈកម្មាធិការឧត្តមសិក្សា កសិកម្ម ។

**ប្រការ២ :** លេខាធិការដ្ឋានអចិន្ត្រៃយ៍មានភារកិច្ច :

ក-ជួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង គណៈកម្មការសិក្សាកសិកម្មក្នុងការ :

- ធ្វើការត្រួតពិនិត្យ វាយតំលៃ និងកែតំរូវ នយោបាយដែលពាក់ព័ន្ធ និងការកំណត់យុទ្ធសាស្ត្រស់រាប់ផ្នែកអប់រំ និងបណ្តុះបណ្តាលកសិកម្ម ។
- ទំនាក់ទំនង និងធ្វើការសហប្រតិបត្តិការ ជាមួយបណ្តាក្រសួងពាក់ព័ន្ធ អ្នកផ្តល់ជំនួយនិងគំរោងផ្សេងៗ ។
- រៀបចំលិខិតគោលនយោបាយអប់រំ លិខិតសំណើ សុំជំនួយពីអ្នកផ្តល់ជំនួយ និងពង្រាងលិខិតស្នាមពិសេសផ្សេងៗ ។
- ធ្វើការរៀបចំបទបញ្ញាទូទៅ និងច្បាប់បទដ្ឋានផ្សេងៗ ដែលជំរុញឱ្យមានការផ្សារភ្ជាប់ រវាងគ្រឹះស្ថានសិក្សាកសិកម្មទាំងឡាយ និងធ្វើឱ្យមានបរិមាណ និងគុណភាពគ្រប់គ្រាន់ នៃធន

ធានមនុស្ស ដែលបណ្តុះបណ្តាលដោយគ្រឹះស្ថានសិក្សាកសិកម្មឱ្យសមស្របតាមល័ក្ខខ័ណ្ឌ តំរូវការទីផ្សារ ។

- រៀបចំការប្រជុំសិក្ខាសាលា និងសន្និបាតផ្សេងៗ ដែលទាក់ទងទៅនឹងការងារអប់រំ និងបណ្តុះបណ្តាលកសិកម្ម ។

- ខ-ជួយសំរបសំរួលការងារគ្រឹះស្ថានសិក្សាកសិកម្ម :

លេខាធិការដ្ឋាននេះ មានភារកិច្ច ក្នុងការជួយជ្រោមជ្រែង គ្រឹះស្ថានសិក្សាកសិកម្មក្នុងការអនុវត្តន៍ យុទ្ធសាស្ត្រសំរាប់ផ្នែកអប់រំនិងបណ្តុះបណ្តាលកសិកម្ម ។ ជាពិសេស ដូចជាទីស្នាក់ការ ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សាកសិកម្ម និងផ្នែកគ្រប់គ្រងរដ្ឋបាលសំរាប់ :

- ជួយគ្រឹះស្ថានសិក្សាក្នុងការបែងចែកធនធានថវិកា ដែលផ្តល់ដោយរដ្ឋាភិបាល ឱ្យមានប្រសិទ្ធភាព និងស្មើភាព សំរាប់ផ្គត់ផ្គង់គ្រឹះស្ថានសិក្សា ។
- ជំនួយក្នុងការធ្វើសហប្រតិបត្តិការ រវាងគ្រឹះស្ថានសិក្សាកសិកម្ម ឱ្យបានល្អ ( ដូចជាការធ្វើឱ្យមានការឯកភាពគ្នានៃប្រព័ន្ធសិក្សារវាងគ្រឹះស្ថានសិក្សានិមួយៗ ) ។
- រៀបចំឯកសារផ្លូវការផ្សេងៗ យោងតាមសំណើសុំរបស់គ្រឹះស្ថានសិក្សា កសិកម្ម ។
- ជំនួយការជំរុញ ទំរង់ការងាររដ្ឋបាល ពីគ្រឹះស្ថានសិក្សាកសិកម្ម មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទៅក្រសួងពាក់ព័ន្ធដទៃទៀត ។
- ចូលរួមចំណែកក្នុងការស្វែងរកអ្នកផ្តល់ជំនួយ និងធ្វើការទំនាក់ទំនង ជាមួយអ្នកផ្តល់ជំនួយផ្សេងៗទៀត ដែលមានការចាប់អារម្មណ៍ក្នុងការផ្តល់ជំនួយឱ្យគ្រឹះស្ថានសិក្សាកសិកម្ម នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ការងារដែលកំណត់ដោយលេខាធិការដ្ឋាន ។
- ធ្វើការសំរបសំរួលអាហារូបករណ៍ សំរាប់បុគ្គលិក មន្ត្រីរាជការ នៃគ្រឹះស្ថានសិក្សាកសិកម្ម ។
- ផ្តល់ពត៌មានទៅឱ្យគ្រឹះស្ថានសិក្សាកសិកម្ម អំពីសំណើសុំផ្តល់សេវាបណ្តុះបណ្តាល ដែលបានស្នើឡើងដោយ ក្រសួងស្ថាប័នពាក់ព័ន្ធនានា អង្គការក្រៅរដ្ឋាភិបាល សហគ្រាសឯកជន និងកម្មវិធីគំរោងនានា ដែលអាចធ្វើបានដោយបុគ្គលិក ឬមន្ត្រីរាជការរបស់គ្រឹះស្ថានសិក្សាកសិកម្ម ដូចជាការផ្តល់សេវាខាងអប់រំបន្ត និងសេវាទីប្រឹក្សាជាដើម ។

- ផ្តល់ការណែនាំ យោងតាមសំណើ របស់គ្រឹះស្ថានសិក្សាកសិកម្ម សំរាប់ធ្វើការអភិវឌ្ឍន៍ និងការផ្តល់សេវាពិសេសផ្សេងៗ ដូចជាការជួយរៀបចំគំរោងសំរាប់ការបណ្តុះបណ្តាល របស់គ្រឹះស្ថានសិក្សាកសិកម្ម ។

គ-ធ្វើការវាយតំលៃទៅលើប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលកសិកម្មទាំងអស់ ជាពិសេសវាយតំលៃទៅលើការរីកចំរើននិងឥទ្ធិពលដែលប៉ះពាល់ទៅលើការអនុវត្តន៍ផែនការជាយុទ្ធសាស្ត្ររបស់គ្រឹះស្ថានសិក្សាកសិកម្មនីមួយៗដោយ :

- ធ្វើការអង្កេតជាទៀងរាល់ឆ្នាំ ដោយប្រើប្រាស់វិធីសាស្ត្រ ត្រួតពិនិត្យ និងវាយតំលៃដែលកំណត់សំរាប់ប្រើប្រាស់ នៅក្នុងប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលកសិកម្ម ។
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ក្នុងការអនុវត្តន៍ និងការប្រព្រឹត្តិទៅរបស់ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលកសិកម្មទាំងមូល ។
- រៀបចំគំរោងផែនការ ការងារអនុវត្តន៍ប្រចាំឆ្នាំសំរាប់ លេខាធិការដ្ឋានអចិន្ត្រៃយ៍អប់រំ និងបណ្តុះបណ្តាលកសិកម្ម ។

ឃ-រៀបចំធ្វើការសិក្សាបន្ថែម ដើម្បីជូនពត៌មានដល់ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំ គ្រឹះស្ថានសិក្សាកសិកម្ម អំពីតំរូវការនៃការផ្លាស់ប្តូរនយោបាយ និងយុទ្ធសាស្ត្រ សំរាប់ការអប់រំ និងបណ្តុះបណ្តាលកសិកម្ម ទៅតាមលក្ខខ័ណ្ឌចាំបាច់របស់ប្រទេសជាតិ ដូចជាការសិក្សាលើតំរូវការទីផ្សារ តាមដានការទទួលយករបស់ទីផ្សារពលកម្មនូវនិស្សិតដែលទើបនឹងបញ្ចប់ការ សិក្សាជាដើម ។ល។

ង-ធ្វើការពង្រឹងគណៈកម្មាធិការសិក្សាកសិកម្ម ។

**ប្រការ៣** : ភារកិច្ចរបស់លេខាធិការដ្ឋាន ដែលមានចែងនៅក្នុងប្រការ៦ ប្រកាសលេខ ១០៣៦ ចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការឧត្តមសិក្សាកសិកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :គ្រឹះស្ថានសិក្សាកសិកម្មទាំងអស់ត្រូវធ្វើការផ្តល់ពត៌មាន និងសហការយ៉ាងជិតស្និតជាមួយលេខាធិការដ្ឋានអចិន្ត្រៃយ៍ អប់រំ និងបណ្តុះបណ្តាលកសិកម្ម ទៅតាមតួនាទី និងភារកិច្ចចាំបាច់របស់លេខាធិការដ្ឋាន ដូចដែលបានកំណត់នៅក្នុងប្រការពីរ ។

**ប្រការ៥** : លេខាធិការដ្ឋានអចិន្ត្រៃយ៍ នេះមានសមាសភាព ០៥រូប ដូចខាងក្រោម :

- ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ចំនួន ០១ រូប
- សមាជិក , ចំនួន ០៤ រូប

សមាជិក លេខាធិការដ្ឋាននេះ ត្រូវតែងតាំងដោយប្រកាសរបស់ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ៦** : តួនាទីភារកិច្ចរបស់ប្រធាន និងសមាជិកលេខាធិការដ្ឋានអចិន្ត្រៃយ៍ :

- អនុប្រធានគណៈកម្មាធិការឧត្តមសិក្សាកសិកម្ម ទទួលបន្ទុក ដឹកនាំការងាររួមរបស់ លេខាធិការដ្ឋានអចិន្ត្រៃយ៍ ។
- ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ទទួលបន្ទុកអនុវត្តន៍ភារកិច្ចក្នុងប្រការ ពីរ ចាប់ពីចំណុច ក ដល់ ង ។
- សមាជិកទាំងអស់របស់លេខាធិការដ្ឋាន ជាជំនួយការឱ្យ ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក្នុងការអនុវត្តន៍ភារកិច្ចដែលមានចែងនៅក្នុងប្រការពីរ ។

**ប្រការ ៧** : ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នេះ មានសិទ្ធិស្វែងរកថវិកា ពីបណ្តាអ្នកផ្តល់ជំនួយផ្សេងៗ សំរាប់ទ្រទ្រង់ការងារដូចដែលបានចែងក្នុងប្រការពីរ ។

**ប្រការ ៨** : លេខាធិការដ្ឋានអចិន្ត្រៃយ៍នេះ អាចប្រើប្រាស់បន្ទុនូវសំភារៈរបស់ផ្នែកអប់រំ និងបណ្តុះបណ្តាលកសិកម្មនៃគំរោងបង្កើនផលិតភាពកសិកម្ម ដូចជា : រថយន្ត ការិយាល័យសំរាប់បំពេញការងារ សំភារៈការិយាល័យ និងសំភារៈទំនាក់ទំនងផ្សេងៗ ។ល។ នៅពេលចប់គំរោងដើម្បីអនុវត្តបន្តតាមភារកិច្ចដែលមានចែងនៅក្នុងប្រការពីរ ។

**ប្រការ ៩** : អគ្គនាយកក្រសួង អគ្គាធិការ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាន គណៈនេយ្យ និងហិរញ្ញវត្ថុ នាយកសាលាកសិកម្មព្រែកលៀប នាយកសាលាកសិកម្មកំពង់ចាម និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**ម៉ៅ សំអឿន**

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ៤៨៤ អយក.ប្រក

## ស្តីពី

## ការកំណត់ខេត្ត-ក្រុងដាច់ស្រយាល

## និងតំបន់ជួបការលំបាក

~~~

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង អប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**ប្រការ ១** :ខេត្ត-ក្រុង ដូចមានរាយឈ្មោះខាងក្រោម ត្រូវបានកំណត់ថា ជាខេត្ត-ក្រុង ដាច់ស្រយាល គឺ :- ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកោះកុង និង ក្រុងប៉ៃលិន ។

**ប្រការ ២** : តំបន់ជួបការលំបាក ត្រូវបានកំណត់តាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- តំបន់ជួបប្រទះការលំបាកខាងគមនាគមន៍
~~~

- ដង់ស៊ីតេប្រជាជនតិចជាង ១០នាក់ ក្នុង១ គីឡូម៉ែត្រក្រឡា
- តំបន់ទឹកលិចអចិន្ត្រៃយ៍
- តំបន់សមាហរណកម្ម ឬតំបន់ជាប់ព្រំដែន
- តំបន់ដែលមានសាលារៀនមិនគ្រប់កំរិត ឬខ្វះគ្រូ ឬមានគ្រូកិច្ចសន្យា

**ប្រការ ៣ :** តំបន់ក្នុងខេត្ត-ក្រុងខាងក្រោម ត្រូវបានកំណត់ថាជាតំបន់ជួបការលំបាក :

**-ខេត្តពោធិ៍សាត់ មាន** : ស្រុកភ្នំក្រវាញ ស្រុកវាលវែង

ស្រុកបាកាន : ឃុំតាលោ

ស្រុកក្រគរ : ឃុំឈើតុំ និង ឃុំស្វាយស

**-ខេត្តកំពង់ធំ មាន** : ស្រុកសណ្ដាន ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ

ស្រុកកំពង់ស្វាយ : ឃុំផាត់សណ្ដាយ

ស្រុកស្ទោង : ឃុំពាមបាង ឃុំពពក ឃុំបន្ទាយស្ទោង និងឃុំចំណាររលើ

ស្រុកបារាយណ៍ : ឃុំគគីធំ និងឃុំបាក់ស្នា

ស្រុកសន្ទុក : ឃុំទីពោ និង ឃុំក្រយា

**-ខេត្តបាត់ដំបង មាន** : ស្រុករតនមណ្ឌល ស្រុកបវេល ស្រុកសំពៅលូន ស្រុកភ្នំព្រឹក្ស ស្រុកកំរៀង ស្រុកគាស់ក្រឡ ស្រុកសំឡូត

ស្រុកឯកភ្នំ : ឃុំកោះជីវាំង និង ឃុំព្រៃចាស់

ស្រុកមោងឫស្សី : ឃុំ ព្រៃត្រឡាច

**-ខេត្តសៀមរាប មាន** : ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកវ៉ារិន ស្រុកអង្គរជុំ ស្រុកអង្គរធំ

ស្រុកបន្ទាយស្រី : ឃុំឃុនរាម ឃុំរំចេក ឃុំត្បែង និងឃុំរន្ធតាអក

ស្រុកជីក្រែង : ឃុំអន្លង់សំណរ ឃុំខ្នាវ ឃុំគោកធ្លកលើ ឃុំពង្រលើ ឃុំពង្រក្រោម ឃុំឫស្សីលក ឃុំល្វែងឫស្សី ឃុំស្ពានត្នោត និងឃុំសង្វើយ

ស្រុកក្រឡាញ់ : ឃុំរោងគោ ឃុំស្នួល ឃុំក្រូចគោ ឃុំសែនសុខ និងឃុំសំបួរ

ស្រុកសូត្រនិគម : ឃុំពពេល ឃុំចាន់សរ ឃុំខ្នារពោធិ៍ ឃុំតាយ៉ែត និងឃុំកំពង់ឃ្លាំង

ស្រុកពួក : ឃុំកែវពិណ ឃុំរើល ឃុំត្រើរ ឃុំល្វា ឃុំយាង ឃុំក្ដិរុន ឃុំពោធិ៍ទ្រាយ និងឃុំដូនកែវ

ស្រុកសៀមរាប : ឃុំនគរធំ និងឃុំចុងឃ្នៀស

ស្រុកប្រាសាទបាគង : ឃុំអំពិល ឃុំបល្ល័ង្គ និងឃុំកំពង់ភ្លុក

**-ខេត្តកំពង់ចាម មាន** : ស្រុកតំបែរ

ស្រុកមេមត់ : ឃុំទ្រាក ឃុំរូង ឃុំចាន់មូល ឃុំជាំ ឃុំជាំក្រវៀន ឃុំទន្លុង ឃុំជាំតាម៉ៅ ឃុំ ត្រម៉ោង ឃុំ មេមង ឃុំគគីរ ឃុំកំពាន់ និង ឃុំរំចេក

ស្រុកស្ទឹងត្រង់ : ឃុំអូរម្លូ ឃុំដងក្ដារ ឃុំ អារក្សត្នោត និងឃុំខ្ពបតាងួន

ស្រុកចំការលើ : ឃុំតាប្រុក និងឃុំចំការអណ្ដូង

ស្រុកត្បូងឃ្មុំ : ឃុំថ្មពេជ្រ ឃុំគរ និងឃុំល្បៀង

ស្រុកពញាក្រែក : ឃុំវាលម្លូរ ឃុំកក់ និងឃុំត្រពាំងផ្លុង

**-ខេត្តបន្ទាយមានជ័យ មាន** : ស្រុកម៉ាឡៃ ស្រុកថ្មពួក ស្រុកភ្នំស្រុក

ស្រុកព្រះនេត្រព្រះ : ឃុំរហាល ឃុំទឹកជោរ ឃុំប្រាសាទ ឃុំទានកាំ និងឃុំភ្នំលៀប

ស្រុកអូរជ្រៅ : ឃុំអូរបីជាន់ ឃុំនិមិត្ត ឃុំសឹង្ហ ឃុំសំរោង និង ឃុំប៉ោយប៉ែត

ស្រុកសិរីសោភ័ណ : ឃុំបុសស្បូវ

ស្រុកមង្គលបូរី : ឃុំសំបូរ ឃុំគោកបល្ល័ង្គ ឃុំសឿ និងឃុំចំណោម

**-ខេត្តកំពង់ស្ពឺ មាន** : ស្រុកថ្ពង ស្រុកឱរ៉ាល់

ស្រុកភ្នំស្រួច : ឃុំមហាសាំង និងឃុំជាំសង្កែ

ស្រុកបរសេដ្ឋ : ឃុំកាត់ភ្លុក ឃុំភក្ដី ឃុំកក់ និង ព្រះខែ

ស្រុកច្បារមន : ឃុំទំព័រមាស និងឃុំតាំងក្រូច

ស្រុកឧដុង្គ : ឃុំជម្ពូព្រឹក

**-ខេត្តក្រចេះ មាន** :

ស្រុកស្នួល : ឃុំស្រែចារ និងឃុំខ្សឹម

ស្រុកសំបូរ : ឃុំរលួស ឃុំស្រែជិះ ឃុំបឹងចារ ឃុំអូគ្រៀង និង ឃុំក្បាលដំរី

ស្រុកឆ្លូង : ឃុំកំពង់ដំរី និងឃុំដំរីផុង

**-ខេត្តកំពត មាន** : ស្រុកដងទុង ស្រុកជុំគីរី

ស្រុកឈូក : ឃុំល្បើក ឃុំកោះស្លា និង ឃុំត្រពាំងឃ្លាំង

ស្រុកកំពត : ឃុំស្ទឹងកែវ ឃុំព្រៃថ្នង់ និង ឃុំតំបន់ជាប់ព្រំដែន

ស្រុកកំពង់ត្រាច :ឃុំឫស្សីស្រុកខាងជើង ឃុំបឹងសាលាខាងត្បូង ឃុំបឹងសាលាខាងជើង និងឃុំព្រែកក្រើស

ស្រុកបន្ទាយមាស : ឃុំត្នោតចុងស្រង់ ឃុំ ព្រៃទន្លេ ឃុំ បន្ទាយមាសខាងលិច ឃុំបន្ទាយមាសខាងកើត និងឃុំស្ដេចគង់ខាងត្បូង

**-ខេត្តតាកែវ មាន** : ស្រុកបូរីជលសារ និង ស្រុកកោះអណ្ដែត

**-ខេត្តកណ្ដាល មាន** :

ស្រុកលើកដែក : ឃុំក្អមសំណ

ស្រុកកោះធំ : ឃុំព្រែកជ្រៃ ឃុំសំពៅពូន និង ឃុំលើកដែក

ស្រុកស្អាង : ឃុំប្រាសាទ

ស្រុកល្វាឯម : ឃុំបារុង ឃុំព្រែកឫស្សី និង ឃុំកោះកែវ

ស្រុកមុខកំពូល : ឃុំស្វាយអំពារ

ស្រុកខ្សាច់កណ្ដាល : ឃុំជ្រៃធំ

ស្រុកពញាឮ : ឃុំកំពង់ហ្លួង និងឃុំកោះចិន

**-ខេត្តព្រៃវែង មាន** : ស្រុកព្រះស្ដេច ស្រុកពាមជរ

ស្រុកកំពង់ត្របែក : សាលារៀននៅក្នុងឃុំជាប់ព្រំដែនវៀតណាម

ស្រុកពារាំង : ឃុំមេប្រចាន់

ស្រុកស៊ីធរកណ្ដាល : ឃុំព្នៅទី ពីរ

**-ខេត្តកំពង់ឆ្នាំង មាន** : ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ស្រុកជលគីរី

ស្រុកកំពង់ត្រឡាច : ឃុំអំពិលទឹក

ស្រុកកំពង់លែង : ឃុំផ្លូវទឹក ឃុំប្រឡាយមាស ឃុំច្រណូក និង ឃុំសំរោងសែន

ស្រុករលាប្អៀរ : ឃុំ ប្រស្នឹប

ស្រុកបរិបូរណ៍ : ឃុំ កំពង់ព្រះ ឃុំគគី ឃុំអញ្ចាញរូង ឃុំប្រពេចចង្វារ និងឃុំត្រពាំងចាន់

-**ខេត្តស្វាយរៀង មាន** : សាលារៀនដែលនៅក្នុងឃុំជាប់ព្រំដែនវៀតណាម

ស្រុកចន្ទ្រា : ឃុំសំរោង ឃុំទួលស្តី ឃុំចន្ទ្រា

ស្រុកស្វាយទៀប : ឃុំមនោរម្យ ឃុំតានី

ស្រុករមាសហែក : ឃុំ គគីរ ឃុំត្រស់ ឃុំអណ្តូងត្របែក និងឃុំសម្បត្តិមានជ័យ

-**ក្រុងកែប មាន** : ខ័ណ្ឌកែប និងខ័ណ្ឌដំណាក់ចង្អើរ

-**ក្រុងព្រះសីហនុ មាន** : ខ័ណ្ឌមិត្តភាព : សង្កាត់កោះកុង

ខ័ណ្ឌព្រៃនប់ : សង្កាត់ព្រៃនប់ ។

**ប្រការ៤** : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានបណ្តុះបណ្តាលវិក្រឹតការ នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុងពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

**តុល ឡោះ**

# ៤~ ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០

**សេចក្តីសំរេច លេខ ១៦៥ ក.ធ.ស.ស.រ**

**ក្រសួងធម្មការ និង សាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃ និកាយ " **សេវេនដាយអាត់វេនទីស្ទ** " នៅខេត្តកំពង់ឆ្នាំងរបស់លោក **ម៉ិត ចាប** អាយុ ៣៧ឆ្នាំ ចុះថ្ងៃទី២៩ ខែ សីហា ឆ្នាំ ២០០០

-យោងចំណារឯកភាព របស់សាលាខេត្តកំពង់ឆ្នាំង លេខ ១៥៣៥ សរសណ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **សេវេនដាយអាត់វេនទីស្ទត្រពាំងព្រាល** " មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិត្រពាំងព្រាល ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **សេវេនដាយអាត់វេន ទីស្ទត្រពាំងព្រាល** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេវេនដាយអាត់វេនទីស្ទត្រពាំងព្រាល** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាត មិនធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ខា សាវឿន**

ភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ១៦៦ ក.ធ.ស.ស.រ

## ក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃ និកាយ " **សេវេនដាយអាត់វេនទីស្ទ** " នៅខេត្តសៀមរាបរបស់លោកស្រី **អែម សារ៉ាន** អាយុ ៤៣ឆ្នាំ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០០

-យោងចំណារឯកភាព របស់សាលាខេត្តសៀមរាប លេខ ២០៨៦ សរ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០០

## សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **សេវេនដាយអាត់វេនទីស្ទគោកពៅ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០៥៧៩ ក្រុមទី០៣ ភូមិគោកពៅ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **សេវេនដាយអាត់វេនទីស្ទគោកពោធិ៍** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេវេនដាយអាត់វេនទីស្ទត្រពាំងព្រាល** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាត មិនធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

---

ភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ១៦៧ ក.ធ.ស.ស.រ

~~~

## ក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
~~~

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃ និកាយ " **សេវេនដាយអាត់វេនទីស្ទ** " នៅខេត្តឧត្តរមានជ័យរបស់លោក **សាលី សាលួត** អាយុ ៤០ឆ្នាំ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០០

-យោងចំណារបញ្ជូន របស់សាលាខេត្តឧត្តរមានជ័យ លេខ ២៤៨ ឧជ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **សេវេនដាយអាត់វេនទីស្ទស្រែប្រាំង** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ឃុំជើងទៀន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **សេវេនដាយអាត់វេនទីស្ទស្រែប្រាំង** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **សេវេនដាយអាត់វេនទីស្ទស្រែប្រាំង** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្សាដាច់ខាត មិនធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការយើអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សារឿន**

ភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០

**សេចក្តីសំរេច លេខ ១៦៨ ក.ធ.ស.ស.រ**

~~~

**ក្រសួងធម្មការ និង សាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត របស់លោក **លក ដី** អាយុ ៣៣ឆ្នាំ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ពួកជំនុំនៃព្រះគ្រិស្តភ្នំពេញ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៣៩ ក្រុមទី១៣ ភូមិទី២ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២** : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ពួកជំនុំនៃព្រះគ្រិស្តភ្នំពេញ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។
~~~

**ប្រការ ៣ :** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ពួកជំនុំនៃព្រះគ្រិស្តភ្នំពេញ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤ :** រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥ :** ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាណិជ្ជសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦ :** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សារឿន**

---

ភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ១៦៩ ក.ធ.ស.ស.រ

~~~

## ក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
~~~

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា " **ឆាប់ទីស្ទ** " នៅខេត្តស្វាយរៀង របស់លោក **គង់សុផា** អាយុ ៣៦ឆ្នាំ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

-យោងចំណារបញ្ជូនរបស់សាលាខេត្តស្វាយរៀង លេខ ២៨ ចប ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៩

**សម្រេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ពាពែត** " មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិ ស្វាយគយ ឃុំពោធិ៍ពែត ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ពាពែត** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ពាពែត** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់ របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្ដីសម្រេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សារឿន**

ភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០០

**សេចក្ដីសម្រេច លេខ ១៧០ ក.ធ.ស.ស.រ**

~~~

**ក្រសួងធម្មការ និង សាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា " **គ្រិស្ទានកម្ពុជា** " នៅខេត្តស្វាយរៀង របស់លោក **អ៊ុក វតនា** អាយុ ២៧ឆ្នាំ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១

-យោងចំណារឯកភាពរបស់សាលាខេត្តស្វាយរៀង លេខ ៥២ ធបស.កិ ចុះថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ ២០០១

**សម្រេច**

**ប្រការ ១** ៖ អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **មេត្តឌីស្ទុតមិទ្ធានសាខ** " មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិប្រាសាទ ឃុំពោធិរាជ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

**ប្រការ ២** ៖ សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **មេត្តឌីស្ទុតមិទ្ធានសាខ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** ៖ បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **មេត្តឌីស្ទុតមិទ្ធានសាខ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង
~~~

ទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ "**នាយកដ្ឋានពាហិរសាសនា**" គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សាវឿន**

---

ភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ១៧១ ក.ធ.ស.ស.រ

## ក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា "**គ្រិស្ទានកម្ពុជា**" នៅខេត្តស្វាយរៀង របស់លោក **គឹម សុនា** អាយុ ៤៨ឆ្នាំ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១

-យោងចំណារឯកភាពរបស់សាលាខេត្តស្វាយរៀង លេខ ៥១ ធបស.កិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **មេត្តូឌីស្តភូមិត្របែក** " មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិត្របែក ឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **មេត្តូឌីស្តភូមិត្របែក** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **មេត្តូឌីស្តភូមិត្របែក** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ខា សារឿន**

ភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០០

**សេចក្ដីសំរេច លេខ ១៧២ ក.ធ.ស.ស.រ**

**ក្រសួងធម្មការ និង សាសនា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងធម្មការ និងសាសនា

-យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដ នៃក្រុមប្រឹក្សា" បាបទីស្ទ " នៅខេត្តស្វាយរៀង របស់លោក **ឡឹក ឈន់** អាយុ ៣២ឆ្នាំ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៨

-យោងចំណារបញ្ជូន របស់សាលាខេត្តស្វាយរៀង លេខ ៣៦ ស.កិ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១** : អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដឈ្មោះ" **ភូមិដក់ពរ** " មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ភូមិដក់ពរ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង ។

**ប្រការ ២** : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ដ " **ភូមិដក់ពរ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ដ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ ៣** : បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ដ " **ភូមិដក់ពរ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ ៤** : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៥** : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្ត សេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៦** : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី.....ខែ.....ឆ្នាំ......

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ជា សារឿន**